**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការក្រុងភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១៣១៤ ចុះថ្ងៃទី ០៣

ខែ តុលា ឆ្នាំ ២០០០

សាលក្រម

លេខ ២៥ "ឆ" ចុះថ្ងៃទី ២៤

ខែ ឧសភា ឆ្នាំ ២០០១

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការក្រុងភ្នំពេញ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។ បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជំរះតុលាការក្រុងភ្នំពេញ នាថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០១ ដែលមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោកស្រី [redacted] ចៅក្រមតុលាការក្រុងភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការក្រុងភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការក្រុងភ្នំពេញ

**មេធាវី**

អ្នកស្រី [redacted] **គីមលន់** មេធាវី

ដើម្បីជំនុំជំរះរឿងព្រហ្មទណ្ឌលេខ ១៣១៤ ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០០ ដែលមានជនជាប់ចោទឈ្មោះ :

១-**ខ ច** ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ សញ្ជាតិកម្ពុជា សាសនាព្រះពុទ្ធ មុខរបរលក់គុយទាវ ការិតវប្បធម៌ មិនចេះអក្សរ កើតនៅភូមិស្វាយព្រះក្រាប ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង ។ ទីលំនៅសព្វថ្ងៃមិនពិតប្រាកដ ឪពុកឈ្មោះ **ខ ព** (ស) ម្តាយឈ្មោះ **ឡ រ** (រ) នៅលីវ ទោសពីមុន *គ្មាន* ។ ចាប់ខ្លួនថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០០ ឃុំខ្លួនថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០០ ។

២-**ស ព** ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ សញ្ជាតិកម្ពុជា សាសនាព្រះពុទ្ធ មុខរបររើសអេតចាយ ការិតវប្បធម៌មិនចេះអក្សរ កើតនៅភូមិបញ្ញា ឃុំបញ្ញា ស្រុកស្វាយរៀង ខេត្តស្វាយរៀង ទីលំនៅសព្វថ្ងៃផ្ទះជួលម្តុំផ្សារដើមថ្កូវរថភ្លើង (ក្នុងវត្តនាគវ័ន្ត) ឪពុកឈ្មោះ **ស ស** (រ) ម្តាយឈ្មោះ **គ ណ** (ស) ប្រពន្ធឈ្មោះ **ឡ សខ** ទោសពីមុន *គ្មាន* ។

ចាប់ខ្លួនថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០០ ឃុំខ្លួនថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០០ ។

ត្រូវជាប់ចោទពីបទ ប្លន់ម៉ូតូ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

*សាលក្រមនេះ ចូលជាសាលក្រមស្ថាពរចាប់ពីថ្ងៃ ២៦ ខែ កក្កដា ឆ្នាំ ២០០១ ដោយគូភាគី*

*ពុំបានចូលមកប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។*

*ភ្នំពេញ.ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០១*

**ក្រឡាបញ្ជី**

[redacted]

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស សទ ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ សញ្ជាតិកម្ពុជា សាសនាព្រះពុទ្ធ មុខរបររត់ម៉ូតូឌុប ទីលំនៅសព្វថ្ងៃផ្ទះលេខ ១៧B ផ្លូវ ៦៣ ក្រុម ៧៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឪពុកឈ្មោះ ស ម (រ) ម្តាយឈ្មោះ ស សរ (រ) នៅលីវ ទោសពីមុន *គ្មាន* ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ៦៧៣៥ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០០ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ ខ ប បានឆ្លើយថា : ខ្ញុំបាទអាចឆ្លើយនូវរឿងហេតុនេះ ដោយខ្លួនឯងបាន ។ នៅយប់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០០ វេលាម៉ោងប្រហែលជា ០១ជាង ខ្ញុំបាទ និង ឈ្មោះ ស ព បានដើរចេញពីមុខវត្តនាគវ័ន្តសំដៅទៅរោងចក្រ MR ខាងត្បូងវត្តដើម្បីទៅរើសអេតចាយ ពេលដើរទៅដល់រោងចក្រ MR ក៏នៅអង្គុយកន្លែងតូបគេលក់ផ្លែឈើ ចំណែកអា ព វាដេក ពេលខ្ញុំបាទអង្គុយនៅទីនោះបានប្រហែលកន្លះម៉ោង ស្រាប់តែមានម៉ូតូ ០១គ្រឿងម៉ាក Windy ពណ៌ក្រហម ជិះគ្នា ០៤នាក់ ក្នុងនោះមានស្រី ០៣នាក់ (ស្រីបា) ពេលនោះម៉ូតូនោះក៏ដាក់ស្រីបា ០៣នាក់នោះចុះចំងាយពីកន្លែងខ្ញុំអង្គុយប្រហែលជាង ១០ម៉ែត្រ ខ្ញុំបាទក៏ស្រែកថា ម៉ូតូឈប់ៗពេលនោះម្ចាស់ម៉ូតូសាងលេខជិះសំដៅទៅខាងត្បូង ជិះបានបន្តិចម៉ូតូធ្លាក់ក្រឡុកដួល ហើយម្ចាស់ម៉ូតូក៏រត់ចោលម៉ូតូ ខ្ញុំបាទក៏បានទាញដើមឫស្សីប៉ុនមេជើងពីតូបលក់ផ្លែឈើទៅកន្លែងម៉ូតូនោះ ហើយម្ចាស់ម៉ូតូបានរត់បាត់ហើយ ឯស្រីបា ០៣នាក់នោះក៏រត់ចូលក្នុងផ្ទះបាត់អស់ ពេលនោះខ្ញុំបាទក៏ដឹកម៉ូតូជាមួយអា ព យកទៅទុកផ្ញើផ្ទះគេមិនស្គាល់នៅក្បែររោងចក្រឆ្លាំង ។ ក្រោយពេលផ្ញើម៉ូតូរួច ខ្ញុំបាទ និង អា ព ក៏មកដេកកន្លែងតូបលក់ផ្លែឈើវិញ ។ ពេលដែលខ្ញុំបាទស្រែកអោយម៉ូតូនោះឈប់ បំណងដើម្បីទារលុយពីស្រីបាយកមកចាយ ដោយខ្ញុំបាទគ្មានគំនិតប្លន់យកម៉ូតូគេឡើយ ព្រោះដៃខ្ញុំបាទមានរបួសជាទម្ងន់ ។ លុះស្អែកឡើងក៏ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនខ្ញុំបាទ ។ ខ្ញុំបាទសុំបដិសេធទាំងស្រុងនូវការយកចម្លើយនៅសមត្ថកិច្ចប៉ូលីស ព្រោះមានការបង្ខំ តែខ្ញុំបាទសុំរក្សាចម្លើយនៅចំពោះមុខលោកព្រះរាជអាជ្ញា ។ ខ្ញុំបាទពុំមានសាក្សីទេក្នុងរឿងក្តីនេះ ។ ខ្ញុំបាទសំណូមពរសុំអោយតុលាការជួយរកយុត្តិធម៌អោយខ្ញុំបាទតាមច្បាប់ ។

-ជនជាប់ចោទឈ្មោះ ស ព បានឆ្លើយថា : ខ្ញុំបាទអាចឆ្លើយនូវរឿងហេតុ នេះដោយខ្លួនឯងបាន ។ នៅយប់ថ្ងៃកើតហេតុនោះ ខ្ញុំបាទដេកនៅរោងគេលក់ផ្លែឈើលើចិញ្ចើមថ្នល់មុខរោងចក្រ MR ក្បែរវត្តនាគវ័ន្ត ដោយដេកជាមួយប្អូនៗខ្ញុំបាទ ។ នៅវេលាម៉ោងពុំចាំ ស្រាប់តែឈ្មោះ ខ ប មកដាស់ខ្ញុំបាទថា ទៅសំឡុតស្រីបាយកលុយខ្ញុំបាទក៏ភ្ញាក់ឡើងឃើញមានម៉ូតូ ០១គ្រឿងជិះគ្នា ០៤នាក់ ស្រី ០៣នាក់ ពេលនោះអា ប ស្រែកថា ឈប់ៗពេលនោះម៉ូតូក៏ភ័យក៏សាងលេខជិះសំដៅមកថ្នល់ធំវិញ ស្រាប់តែជិះបានបន្តិចម៉ូតូនោះដួល ឯស្រីៗរត់ចូលផ្ទះពេលនោះអា ប មានមែកឫស្សី ១ដើមកាន់ទៅកន្លែងម៉ូតូដែលដួល ពេលទៅដល់ពុំឃើញម្ចាស់ម៉ូតូទេ អា ប ក៏ហៅខ្ញុំអោយមកលើកយកម៉ូតូនោះបណ្តើរយកមកផ្ញើទុកផ្ទះយាយ ព នៅក្បែររោងចក្រឆ្លាំង ក្រោយពីផ្ញើទុកផ្ទះយាយ ព ហើយខ្ញុំបាទ និង អា ប ក៏មកដេកកន្លែងដើមវិញ ។ ខ្ញុំបាទគ្មានបំណងសំឡុតគំរាមយកម៉ូតូគេឡើយ គឺអា ប វាដាស់ខ្ញុំបាទពីដំណេក ដើម្បីសំឡុតយកលុយពីស្រីបាតែប៉ុណ្ណោះ ។

ខ្ញុំបាទសុំបដិសេធនូវការចោទប្រកាន់ របស់លោកព្រះរាជអាជ្ញាទាំងស្រុង ។ ក្នុងរឿងក្តីនេះខ្ញុំគ្មានសាក្សីឡើយ ។ ខ្ញុំបាទសំណូមពរសុំអោយតុលាការ ជួយរកយុត្តិធម៌អោយខ្ញុំបាទតាមច្បាប់ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស សទ បានឆ្លើយថា : ខ្ញុំបាទអាចឆ្លើយនូវរឿងហេតុនេះដោយខ្លួនឯងបាន ពុំចាំបាច់មានមេធាវីឡើយ ។ កាលពីថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០០ វេលាម៉ោងប្រហែលជាង ១២យប់រំលង

អធ្រាត្រ ខ្ញុំបាទបានឌុបស្រីចំនួន ០៣នាក់ពីកាច់ជ្រុងផ្សារចាស់សំដៅទៅវត្តនាគវ័ន្ត ដោយស្រី ០៣នាក់នោះអោយតម្លៃឈ្នួលឌុបចំនួន ៣.០០០រៀល ។ ពេលដែលខ្ញុំបាទជូនស្រី ០៣នាក់ នោះទៅដល់ផ្ទះគេហើយ ខ្ញុំបាទក៏ជិះម៉ូតូម្នាក់ឯងចេញមកវិញបានប្រហែលជាង ១០ម៉ែត្រ ត្រង់ចំណុចមុខរោងចក្រ MR (រោងចក្រជួសជុលទូរថភ្លើង) ខ្ញុំបាទឃើញ ម ានមនុស្សប្រុសចំនួន ០២នាក់ឈរក្បែរទូរថភ្លើង ពេលនោះមានមនុស្សប្រុសម្នាក់រាងខ្ពស់ស្តើង សក់ស្លូតពាក់អាវការ៉ូដៃវែង កាន់ដំបងប្រវែងប្រហែល ០៤តឹកទំហំប៉ុនកដៃមនុស្សចាស់ស្ទុះមកវាយតម្រង់ក្បាលខ្ញុំបាទ ពេលនោះខ្ញុំបាទគេចផុតជិះម៉ូតូបានប្រហែល ០៤ម៉ែត្រម៉ូតូខ្ញុំបាទក៏ធ្លាក់ក្រឡុកដួល ខ្ញុំបាទក៏រត់ដោះខ្លួន និង ស្រែកអោយគេជួយតែពុំមានអ្នកណាជួយឡើយ ពេលខ្ញុំបាទរត់បានជាង ១០ម៉ែត្រ ក៏ជនល្មើស ០២នាក់នោះលើកយកម៉ូតូរបស់ខ្ញុំបាទដោយអាម្នាក់ជិះ អាម្នាក់រុញពីក្រោយ ។ ក្រោយពីជនល្មើសលើកយកម៉ូតូខ្ញុំបាទយកទៅខ្ញុំបាទក៏ដើរមកថ្នល់ធំ ហើយក៏បានប្តឹងប៉ូលីសក្រុមខ្លាហោះទាំងយប់អោយជួយដើររកតែរកពុំឃើញឡើយ លុះស្អែកឡើងខ្ញុំបាទក៏មកប្តឹងប៉ូលីសប៉ុស្តិ៍សង្កាត់ផ្សារដេប៉ូទី ២ ។

ខ្ញុំបាទសំណូមពរសុំអោយធ្វើការផ្តន្ទាទោសជនល្មើសទាំង ០២នាក់តាមផ្លូវច្បាប់ និង សំណូមពរសុំយកម៉ូតូវិញដើម្បីបានរត់ឌុបដោះស្រាយជីវភាព ។

ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ **ច ២** បានឆ្លើយថា : នាងខ្ញុំសូមបំភ្លឺជូនសមត្ថកិច្ចអោយបានជ្រាបថា : វេលាម៉ោង ០១ និង ២០នាទី នៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០០ នាងខ្ញុំកំពុងដេកនៅមុខរោងចក្រជួសជុល ទូររទេះភ្លើងជិតកន្លែងកើតហេតុ ពេលនោះខ្ញុំឃើញជនរងគ្រោះបានជិះម៉ូតូចេញពីមុខរោងចក្រជួសជុលរទេះភ្លើង ពេលនោះខ្ញុំឃើញជនល្មើសចំនួន ០២នាក់ គឺមួយឈ្មោះអា **៣** ភេទប្រុស រាងខ្មៅ មានម្រាមដៃព្រែក និង ជនល្មើសមួយទៀតឈ្មោះអា **២** រាងខ្ពស់ ពេលនោះឈ្មោះអា **៣** ដែលជាអ្នកដៃដល់កាន់ដំបង ០១ដើមប្រវែង ០៤តឹក ពេលនោះជនល្មើសបានចេញមកស្ទាក់ផ្លូវជនរងគ្រោះដែលកំពុងជិះចេញពីរោងចក្រ រួចហើយជនរងគ្រោះឃើញជនល្មើសស្ទាក់ផ្លូវ ក៏ផ្ទួលម៉ូតូចោល រួចក៏រត់ចោលម៉ូតូ បន្ទាប់មកជនរងគ្រោះក៏ស្រែកអោយគេជួយ ជនរងគ្រោះស្រែក រួចហើយក៏រត់ទៅខាងមុខផ្លូវលេខ ១៣២ រួចហើយជនល្មើសក៏បានម៉ូតូមកបាក់ជិះ តែម៉ូតូនោះមិនឆេះ ក៏ឈ្មោះអា **៣** ជាអ្នកជិះហើយអា **២** ជាអ្នករុញពីខាងក្រោយ រួចហើយជនល្មើសទាំង ០២ បាននាំគ្នាបណ្តើរ ហើយរុញម៉ូតូនោះទៅខាងផ្លូវទៅខាងកើត គឺតាមផ្លូវវត្តនាគវ័ន្ត រួចហើយជនល្មើសទាំង ២ មិនដឹងជាយកម៉ូតូនោះយកទៅទុកឯណាទេ ជនល្មើសត្រឡប់មកវិញ ដោយមានរទេះមួយរុញធ្វើជាអ្នករើសអេតចាយ បន្ទាប់មកមានម៉ូតូខ្លាហោះ ០១គ្រឿង តែខ្ញុំមិនបានមើលផ្លាកលេខទេ ក៏បានសួរជនល្មើសទាំងពីរ អា **៣** វាបានឡើងដេក រួចហើយម៉ូតូខ្លាហោះ ក៏បាននិយាយជាមួយអា **២** រួចហើយក៏បានគំរាមថាអញយកឯងទៅខណ្ឌ រួចហើយម៉ូតូខ្លាហោះ ក៏បានដឹកអា **២** ទៅបាត់ លុះព្រឹកម៉ោងប្រហែលជា ៦ និង ៣០ នាទី ក៏ឮថាប៉ូលីសឈ្មោះអា **ចរ** បានដាក់ខ្នោះអា **២** ដើម្បីនាំទៅយកម៉ូតូ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន : ឆ្លងតាមរយៈសវនាការឃើញថា ផ្អែកលើចម្លើយជនល្មើស ចម្លើយដើមបណ្តឹង ចម្លើយសាក្សី មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ខ ២** និង ឈ្មោះ **ស ៣** ពិតជាបានប្រព្រឹត្តអំពើប្លន់ម៉ែន បទល្មើសមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០០ ។

-សូមប្រគល់សិទ្ធិអោយតុលាការវិនិច្ឆ័យតាមច្បាប់ ។

**-មេធាវី :** ឆ្លងតាមការសួរដេញដោលនាពេលសវនាការ កូនក្តីរបស់ខ្លួនបានឆ្លើយហើយ ពុំមានគំនិតប្លន់ទេបំណងគឺសុំលុយ បើសិនជាកូនក្តីខ្ញុំប្លន់យកម៉ូតូមែននោះ គឺកូនក្តីខ្ញុំគេចខ្លួនបាត់ហើយ តែដោយរយៈពេលខ្លីពេក កូនក្តីខ្ញុំបានយកម៉ូតូទៅផ្ញើគេនៅផ្ទះជិតកន្លែងកើតហេតុ កូនក្តីខ្ញុំគ្មានចេតនាយកម៉ូតូទៅលក់ទេ កូនក្តីខ្ញុំមិនចេះអក្សរ ខ្វះការ

អប់រំ ឈ្មោះ ស ព គ្មានឪពុកម្តាយ ដោយឈ្មោះ ម ហៅអោយជួយលើកម៉ូតូតែប៉ុណ្ណោះ អំពើនេះកូនក្តីខ្ញុំ ទើបតែប្រព្រឹត្តជាលើកទី ១ ពិនិត្យមាត្រា ៦៨ និង មាត្រា ១៤ ឃុំខ្លួនលើសកំហុសនីតិវិធីរបស់តុលាការ ខ្ញុំសូមអោយតុលាការបន្ធូរបន្ថយទោសកូនក្តីខ្ញុំទាំងពីរអោយបានទាបបំផុត ។

-សំដីចុងក្រោយរបស់ជនល្មើសឈ្មោះ ខ ម និង ឈ្មោះ ស ព សុំសំណូមពរអោយតុលាការជួយរកយុត្តិធម៌ និង បន្ធូរបន្ថយទោសដល់គេផង ។

-ក្រោយពីបានស្តាប់ចម្លើយជនល្មើស

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹង

-ក្រោយពីបានអានចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់អយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

តុលាការក្រុងភ្នំពេញ ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ ។

## យល់ឃើញថា

-ឈ្មោះ ខ ម អាយុ ១៩ឆ្នាំ និង ឈ្មោះ ស ព អាយុ ១៩ឆ្នាំ ជាសមត្ថជន ។

-យប់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០០ ឈ្មោះ ខ ម និង ស ព បានពួនស្ទាក់ហៅម៉ូតូឌុប ១គ្រឿង ដែលជិះចេញពីមុខរោងចក្រជូសជុលទូរថភ្លើងក្នុងបំណងប្លន់ ។

-ក្នុងពេលធ្វើសកម្មភាព បក្សពួកជនល្មើស ដោយមានកាន់ដំបងឈើ ០១ដើម បានវាយទៅលើជនរងគ្រោះសំដៅក្បាល តែត្រូវជនរងគ្រោះគេចទាន់ ម៉ូតូក៏ធ្លាក់ជង្ហុកដួល ជនរងគ្រោះរត់គេចខ្លួនចោលម៉ូតូ ពួកវាក៏នាំគ្នារុញម៉ូតូយកទៅតែម្តងទៅ ។

-ការប្រើហឹង្សាដោយអាវុធ គំរាមកំហែងទៅលើជនរងគ្រោះ ទោះបីមិនបណ្តាលអោយមានរបួស ដើម្បីដកហូតយកទ្រព្យសម្បត្តិអ្នកដទៃ គឺជាអំពើប្លន់ ។

-យល់ឃើញថា :មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ខ ម និង ឈ្មោះ ស ព ពីបទប្លន់ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០០ ។

មាត្រា ៣៤ ចែងថា :

១-ជនណាដែលបានលួច ឬប៉ុនប៉ងលួចជនណាម្នាក់ទៀត ដោយមានស្ថានទម្ងន់ទោសទាំងនេះ :

-ការធ្វើដោយអំពើហឹង្សា មានអាវុធ បណ្តាល ឬ មិនបណ្តាលអោយមានរបួស ។

-រីការលួចនោះបានធ្វើឡើងដោយមានគ្នាច្រើន ឬ ដោយមានតាស់ទម្លុះទម្លាយ ត្រូវមានទោសពីបទឧក្រិដ្ឋប្លន់ ហើយត្រូវផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី ០៣ឆ្នាំ ទៅ ១០ឆ្នាំ ។

២-អំពើលួចប្លន់ ឬ ការបន្លំយកទ្រព្យសម្បត្តិរបស់អ្នកដទៃ ក្នុងបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។

-ទោះបីមានកំហុសផ្នែកនីតិវិធីទី ២ តែជននេះបានប្រព្រឹត្តបទឧក្រិដ្ឋដែលប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់សង្គម ។

-ជនជាប់ចោទមិនសារភាពស្មោះត្រង់ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ស សខ ប្ដឹងសុំតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ និង ទាមទារម៉ូតូរបស់ខ្លួនវិញ ។

-វត្ថុតាងមាន : ម៉ូតូ ០១គ្រឿង ម៉ាកវិនឌី ពណ៌ក្រហម លេខតួគ្មាន លេខម៉ាស៊ីន ៥៥៧៩៦៨ ជារបស់ជនរងគ្រោះឈ្មោះ **ស សខ** ។

<u>**ហេតុដូច្នេះសំរេច**</u>

១-ផ្ដន្ទាទោស :

ក-ឈ្មោះ **ខ ម** ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ សញ្ជាតិកម្ពុជា សាសនាព្រះពុទ្ធ មុខរបរ លក់តុយទាវ កសិកម្មប្បធម៌មិនចេះអក្សរ កើតនៅភូមិស្វាយព្រះក្រាប ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង ទីលំនៅសព្វថ្ងៃ មិនពិតប្រាកដ ឪពុកឈ្មោះ **ខ ព** (ស) ម្ដាយឈ្មោះ **ឡ រ** (រ) នៅលើវ ទោសពីមុន *គ្មាន* ចាប់ខ្លួនថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០០ ឃុំខ្លួនថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០០ ។

ខ-ឈ្មោះ **ស ព** ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ សញ្ជាតិកម្ពុជា សាសនាព្រះពុទ្ធ មុខរបរ រើសអេតចាយ កសិកម្មប្បធម៌ មិនចេះអក្សរ កើតនៅភូមិបញ្ញា ឃុំបញ្ញា ស្រុកស្វាយរៀង ខេត្តស្វាយរៀង ទីលំនៅសព្វថ្ងៃផ្ទះជួលមុំថ្នល់រថភ្លើង (វត្តនាគវ័ន្ត) ឪពុកឈ្មោះ **ស ស** (រ) ម្ដាយឈ្មោះ **ក ឆរ** (ស) ប្រពន្ធឈ្មោះ **ឡ សខ** ទោសពីមុន *គ្មាន* ចាប់ខ្លួនថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០០ ឃុំខ្លួនថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០០ ។ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ០៣ឆ្នាំ (បីឆ្នាំ) គិតពីថ្ងៃឃុំខ្លួនពីបទប្លន់បទល្មើសមានថែង និង ផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០០ ។

២-វត្ថុតាងមាន : ម៉ូតូ ០១គ្រឿង ម៉ាកវិនឌី ពណ៌ក្រហម លេខតួគ្មាន លេខម៉ាស៊ីន ៥៥៧៩៦៨ ជារបស់ជនរងគ្រោះ ត្រូវប្រគល់អោយជនរងគ្រោះឈ្មោះ **ស សខ** វិញ ។

៣-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជី** | **ចៅក្រមជំនុំជំរះ**

[redacted] | [redacted]